**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ: ៨៩៨ សហវ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ ២០០២

**ប្រកាស**

**ស្តីពី**

**ការបង្កើតគណៈកម្មការពិនិត្យការដេញថ្លៃ**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៨/៨៨ ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងឥស្សរជនជាអនុរដ្ឋលេខាធិការនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាននៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៨/៩៩ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ
- បានឃើញ អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ១:** បង្កើតគណៈកម្មការមួយដែលមានឈ្មោះថា «គណៈកម្មការពិនិត្យការដេញថ្លៃ» ដើម្បីជ្រើសរើសក្រុមហ៊ុន ឬ អង្គការឱ្យរៀបចំ និងអនុវត្តគំរោងស្វ័យប្រវត្តិកម្មគយ-រដ្ឋាករ ។

**ប្រការ២:** គណៈកម្មការដេញថ្លៃនេះ មានសមាសភាពដូចខាងក្រោមៈ

| | | |
|---|---|---|
| ១. ឯកឧត្តម **ប៉ែន ស៊ីម៉ន** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ | ប្រធាន |
| ២. ឯកឧត្តម **សួរ ឫទ្ធិច័ន្ទ** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣. លោក **គុណា ញឹម** | នាយករងទីចាត់ការគយ និងរដ្ឋាករ | សមាជិក |
| ៤. លោក **ម៉ែន សំអាត** | ប្រធានការិយាល័យលេខាធិការ | សមាជិក |

៥. លោក ឌុយ សារិន ប្រធានការិយាល័យត្រួតពិនិត្យ សមាជិក

៦. លោក ជា ហាក់ ប្រធានការិយាល័យតំលៃ ស្ថិតិ និងឯកសារ សមាជិក

៧. លោក ម៉ុល គីមសែន ភ្នាក់ងារតយ-រដ្ឋាករនៃការិយាល័យស្ថិតិ និងពត៌មានវិទ្យា លេខាធិការ

**ប្រការ ៣** : គណៈកម្មការពិនិត្យការដេញថ្លៃមានភារកិច្ចដូចតទៅ ÷

១. ពិនិត្យ និងវាយតំលៃតាមលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសក្រុមហ៊ុនឬ អង្គការ ដែលត្រូវរៀបចំ និងអនុវត្តគំរោងស្វ័យប្រវត្តិកម្មគយ-រដ្ឋាករ ។

២. ផ្តល់អនុសាសន៍ និងស្នើសុំសេចក្តីសំរេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលើលទ្ធផលនៃការពិនិត្យ និងវាយតំលៃលើឯកសាររបស់ក្រុមហ៊ុនឬអង្គការដាក់ពាក្យចូលដេញថ្លៃ ។

៣. ធ្វើការចរចាជាមួយក្រុមហ៊ុនឬអង្គការដែលត្រូវបានជ្រើសរើស ដើម្បីរៀបចំគំរោង និងកិច្ចសន្យាស្តីពីគំរោងស្វ័យប្រវត្តិកម្មគយ ។

៤. រៀបចំនូវលិខិតបទដ្ឋានផ្សេងៗ ពាក់ពន្ធ័នឹងការអនុវត្តន៍គំរោងស្វ័យប្រវត្តិកម្មគយ ។

៥ . គៀងគរជំនួយបច្ចេកទេស និងហិរញ្ញវត្ថុតាមនិតិវិធី ដើម្បីអនុវត្តគំរោងនេះ ។

**ប្រការ ៤**: គណៈកម្មការពិនិត្យការដេញថ្លៃត្រូវធ្វើការជាមួយអ្នកជំនាញការ IMF អមទីចាត់ការគយ និងរដ្ឋាករ និងមានសិទ្ធិអញ្ជើញមន្ត្រីជំនាញពាក់ពន្ធ័មកប្រជុំពិគ្រោះយោបល់។

**ប្រការ ៥** : គណៈកម្មការពិនិត្យការដេញថ្លៃ បំពេញការងារក្រោមការត្រួតពិនិត្យដោយផ្ទាល់របស់ប្រធានគណៈកម្មការនេះ ។

**ប្រការ ៦**: ប្រកាស ឬសេចក្តីសំរេចណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧**: ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ និងសាម៉ីខ្លួន ត្រូវទទួលអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**...ទេសរដ្ឋមន្ត្រី**

**...សេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

<u>ចំលងជូន:</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរជាតិសវនកម្ម
- ដូចប្រការ៧ «ដើម្បីអនុវត្ត»
- កាលប្បវត្តិ/ឯកសារ